អាជ្ញាធរមីន
C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
# នៅខែតុលា ឆ្នាំ២០២៤

## សារតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

### ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### ១-ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែតុលា ឆ្នាំ២០២៤

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែតុលា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥.០៨២នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.២០៤នាក់(៧៩%) និងស.ផ.ស. ១៣.៨៧៨នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩.៨៣២នាក់(៣០%) របួស ៣៦.១៥៤នាក់(៥៦%) និងពិការអវយវៈ ៩.០៩៦នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២.៧០១នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.១២៣នាក់(៩%) ស្ត្រី ៤.៧៩៧នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩៨នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)។

### ២- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២៧ករណី ដែលតួលេខនេះថយចុះ ៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៩ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៧ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១៧ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ១០ករណី។

### ៣- ជនរងគ្រោះពីខែមករា ដល់ខែតុលា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៤៥នាក់។ តួលេខនេះបានកើនឡើង ៥៥% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានជនរងគ្រោះចំនួន ២៩នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ៤៥នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ២០នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ២៥នាក់
- ជនរងគ្រោះស្លាប់ ១០នាក់ របួស ២៧នាក់ និងពិការអវយវៈ ៨នាក់
- ជនរងគ្រោះជាបុរស ២៦នាក់ ជាស្ត្រី ៣នាក់ ជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ១១នាក់ និងជាក្មេងស្រីអាយុក្រោម១៨ឆ្នាំ ៥នាក់។

## ៤- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែតុលា ឆ្នាំ២០២៤

នៅខែតុលា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ១ករណី បានកើតឡើងនៅខេត្តកំពត។ តួលេខនេះមានការថយចុះ ៥០% បើប្រៀបធៀបនឹងខែតុលា ឆ្នាំ២០២៣ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីនចំនួន ២ករណី។

ព័ត៌មានអំពីឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែតុលា ឆ្នាំ២០២៤

- ឧប្បត្តិហេតុគ្រោះថ្នាក់បានកើតឡើងនៅក្នុងភូមិ។

## ៥- ជនរងគ្រោះក្នុងខែតុលា ឆ្នាំ២០២៤

នៅខែតុលា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦នាក់។ តួលេខនេះមានការកើនឡើង ២០០% បើប្រៀបធៀបនឹងខែតុលា ឆ្នាំ២០២៣ ដែលមានជនរងគ្រោះ ២នាក់។

- ជនរងគ្រោះ ៦នាក់ បានរងរបួសដោយសារស.ផ.ស.
- ជនរងគ្រោះ ១នាក់ជាបុរស ២នាក់ជាក្មេងប្រុសអាយុក្រោម ១៨ឆ្នាំ ២នាក់ជាក្មេងស្រីអាយុក្រោម ១៨ឆ្នាំ និង ជនរងគ្រោះ ១នាក់ជាស្ត្រី
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖ ការនៅក្បែរកន្លែងកើតហេតុ។

## ៦- ផលប៉ះពាល់ពីតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤ (ជនរងគ្រោះ ៧៧នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៣% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៥% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៤% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

## ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅខែតុលា ឆ្នាំ២០២៤
## ឧប្បត្តិហេតុ ១ករណី ជនរងគ្រោះ ៦នាក់




**Produced by CMVIS, Nov 2024**

ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែលៈ ketya@cmaa.gov.kh

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ២០២១ ដល់ខែតុលា ឆ្នាំ២០២៤

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2021** | **6** | **5** | **2** | **8** | **5** | **0** | **4** | **3** | **1** | **8** | **0** | **2** | **44** |
| *ការបូកបណ្តាក់ ឆ្នាំ2021* | *6* | *11* | *13* | *21* | *26* | *26* | *30* | *33* | *34* | *42* | *42* | *44* | |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការបូកបណ្តាក់ ឆ្នាំ2022* | 11 | 20 | 27 | 34 | 39 | 40 | 40 | 40 | 40 | 40 | 40 | 41 | |
| *ការប្រែប្រួលភាគរយ 2021 ធៀប 2022* | 83 | 82 | 108 | 62 | 50 | 54 | 33 | 21 | 18 | -5 | -5 | -7 | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | **1** | **2** | **1** | **2** | **32** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2022* | -8 | -4 | -3 | -7 | 2 | 1 | 2 | 3 | 1 | 2 | 1 | 1 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2022* | -73 | -44 | -43 | -100 | 40 | 100 | 100 | 100 | 100 | 100 | 100 | 100 | |
| *ការបូកបណ្តាក់ ឆ្នាំ2023* | ***3*** | ***8*** | ***12*** | ***12*** | ***19*** | ***21*** | ***23*** | ***26*** | ***27*** | ***29*** | ***30*** | ***32*** | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | -33 | -28 | -25 | -22 | |
| **2024** | **3** | **3** | **5** | **12** | **7** | **5** | **2** | **1** | **1** | **6** | | | **45** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2023* | 0 | -2 | 1 | 12 | 0 | 3 | 0 | -2 | 0 | 4 | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2023* | 0 | -40 | 25 | 100 | 0 | 150 | 0 | -67 | 0 | 200 | | | |
| *ការបូកបណ្តាក់ ឆ្នាំ2024* | ***3*** | 6 | ***11*** | ***23*** | ***30*** | ***35*** | ***37*** | ***38*** | ***39*** | ***45*** | | | |
| *ការប្រែប្រួលភាគរយ 2023 ធៀប 2024* | 0 | -25 | -8 | 92 | 58 | 67 | 61 | 46 | 44 | 55 | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀត នៃដំណើរការប្រមូលទិន្នន័យនឹងស្រាវជ្រាវឱ្យទាន់ពេលវេលា



## ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤

### រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ២០២៣ និងឆ្នាំ២០២៤

| | មករា23 | កុម្ភៈ23 | មីនា23 | មេសា23 | ឧសភា23 | មិថុនា23 | កក្កដា23 | សីហា23 | កញ្ញា23 | តុលា23 | វិច្ឆិកា 23 | ធ្នូ23 | សរុប2023 | មករា24 | កុម្ភៈ24 | មីនា24 | មេសា24 | ឧសភា24 | មិថុនា24 | កក្កដា24 | សីហា24 | កញ្ញា24 | តុលា24 | វិច្ឆិកា 24 | ធ្នូ24 | សរុប2024 | សរុប | ការបូកបណ្តាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្តាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2023-2024** | | | |
| បាត់ដំបង | 0 | 0 | 0 | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 2 | **6** | 0 | 1 | 2 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | **10** | 10 | 13 | 13 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 3 | 0 | 1 | 0 | 0 | 1 | 0 | 0 | **5** | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | **5** | **10** | 20 | 13 | 26 |
| ឧត្តរមានជ័យ | 0 | 1 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 1 | 0 | **5** | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 29 | 11.7 | 38 |
| មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **6** | **6** | 35 | 7.8 | 45 |
| ព្រះវិហារ | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | **4** | **6** | 41 | 7.8 | 53 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | **6** | **6** | 47 | 7.8 | 61 |
| ពោធិ៍សាត់ | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 3 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 52 | 6.5 | 68 |
| កំពង់ធំ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 57 | 6.5 | 74 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 62 | 6.5 | 81 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 1 | 0 | 0 | **3** | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | **2** | **5** | 67 | 6.5 | 87 |
| រតនគិរី | 0 | 3 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **4** | 71 | 5.2 | 92 |
| សៀមរាប | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 73 | 2.6 | 95 |
| ព្រះសីហនុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 74 | 1.3 | 96 |
| តាកែវ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 75 | 1.3 | 97 |
| ក្រចេះ | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 76 | 1.3 | 99 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **1** | **1** | 77 | 1.3 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| កណ្ដាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 77 | 0 | 100 |
| **សរុប** | 3 | 5 | 4 | 0 | 7 | 2 | 2 | 3 | 1 | 2 | 1 | 2 | **32** | 3 | 3 | 5 | 12 | 7 | 5 | 2 | 1 | 1 | 6 | 0 | 0 | **45** | **77** | | | |



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤

| លំដាប់ | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្ដាក់លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 8 | 2 | **10** | 10 |
| 2 | បាត់ដំបង | 8 | 2 | **10** | 20 |
| 3 | ឧត្តរមានជ័យ | 8 | 1 | **9** | 29 |
| 4 | កំពត | 0 | 6 | **6** | 35 |
| 5 | មណ្ឌលគិរី | 0 | 6 | **6** | 41 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្ដាក់លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 5 | 1 | **6** | 6 |
| 2 | បន្ទាយមាស | កំពត | 0 | 6 | **6** | 12 |
| 3 | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 18 |
| 4 | អន្លង់វែង | ឧត្តរមានជ័យ | 5 | 1 | **6** | 24 |
| 5 | វាលវែង | ពោធិ៍សាត់ | 5 | 0 | **5** | 29 |
| 6 | សំឡូត | បាត់ដំបង | 5 | 0 | **5** | 34 |
| 7 | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 38 |
| 8 | អូរជ្រៅ | បន្ទាយមានជ័យ | 4 | 0 | **4** | 42 |
| 9 | អូរយ៉ាដាវ | រតនគិរី | 1 | 3 | **4** | 46 |
| 10 | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 50 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះមីន | អ្នករងគ្រោះសំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុបអ្នករងគ្រោះ | ការបូកបណ្ដាក់លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ទូកមាសខាងលេច | បន្ទាយមាស | កំពត | 0 | 6 | **6** | 6 |
| 2 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្តរមានជ័យ | 5 | 1 | **6** | 12 |
| 3 | រមនា | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 18 |
| 4 | អូរបីជាន់ | អូរជ្រៅ | បន្ទាយមានជ័យ | 4 | 0 | **4** | 22 |
| 5 | រុងរឿង | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 26 |
| 6 | ឆ្នុកទ្រូ | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 30 |
| 7 | ថ្មដា | វាលវែង | ពោធិ៍សាត់ | 4 | 0 | **4** | 34 |
| 8 | យ៉ាទុង | អូរយ៉ាដាវ | រតនគិរី | 0 | 3 | **3** | 37 |
| 9 | គោករមៀត | ថ្មពួក | បន្ទាយមានជ័យ | 3 | 0 | **3** | 40 |
| 10 | តាតោក | សំឡូត | បាត់ដំបង | 2 | 0 | **2** | 42 |

# ការឆ្លុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេលៈ មករា ឆ្នាំ២០២៣ - តុលា ឆ្នាំ២០២៤

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍ៈ **៧៧**

## ការបែងចែកតាមប្រភេទយុទ្ធភណ្ឌគ្រឿងផ្ទុះ




## មូលហេតុបណ្ដាលឱ្យរងគ្រោះ




## លក្ខណៈនៃអ្នករងគ្រោះ




## ការឆ្លុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












អំឡុងពេល: ខែមករា ឆ្នាំ២០២៣ - ខែតុលា ឆ្នាំ២០២៤

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍: **៧៧**

## <u>សកម្មភាពដែលបណ្តាលឱ្យគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ</u>

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 51 | 4 | 22 | 77 |




## <u>សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ</u>

### សកម្មភាពដែលបណ្តាលឱ្យផ្ទុះមីន




### សកម្មភាពដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម




## <u>ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី</u>

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

